# ឯកឧត្តម ទេសរដ្ឋមន្ត្រី ជួបប្រតិភូអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ **(OECD)**



នៅរសៀលថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម បានទទួលជួបប្រតិភូនៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) រួមមានលោក **Marcos Bonturi** នាយកទំនាក់ទំនងសកល និងលោក **Alexender Böhmer** ប្រធានទទួលបន្ទុកនាយកដ្ឋានអាស៊ីអាគ្នេយ៍ ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។



លោក **Marcos Bonturi** នាយកទំនាក់ទំនងសកល និងលោក **Alexender Böhmer** ប្រធានទទួលបន្ទុកនាយកដ្ឋានអាស៊ីអាគ្នេយ៍ បានជម្រាបជូនពីគោលបំណងនៃជំនួបពិភាក្សា ដោយផ្តោតទៅលើទម្រង់គោលនយោបាយ

អាទិភាពលើសហគ្រាសធុនតូច និងមធ្យម (SME) របស់ប្រទេសកម្ពុជា និងកិច្ចការណាខ្លះដែលអង្គការ OECD អាចសហការជួយដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីឈានដល់ការសម្រេចគោលដៅរបស់ក្រសួង ស្តីពីការអភិវឌ្ឍន៍វិស័យសហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា ។ លោក **Marcos Bonturi** បានបន្ថែមថា: ទាក់ទងក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអាស៊ានទទួលបន្ទុកវិស័យ SME អង្គការ OECD និងវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) បានសហការជួយគាំទ្រគម្រោង ស្តីពីសន្ទស្សន៍គោលនយោបាយសហគ្រាសធុនតូច និងមធ្យមអាស៊ាន ឆ្នាំ២០១៤ (ASEAN SME Policy Index 2014) ហើយគ្រោងនឹងរៀបចំកិច្ចប្រជុំមួយនាថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៤ ហៅថា: កិច្ចប្រជុំតុមូលលើកទី២លើគោលនយោបាយ SME តំបន់ ASEAN -OECD(2nd OECD-ASEAN Regional SME Policy Rountable) ស្របពេលជាមួយកិច្ចប្រជុំក្រុមការងារ SME អាស៊ានលើកទី៣៥ នៅខេត្តសៀមរាប ក្នុងគោលបំណងសំខាន់ពីរ គឺ **ទី១:** ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងភាពជោគជ័យ ក្នុងការអនុវត្តល្អជាអន្តរជាតិ ពីបណ្តាប្រទេសអភិវឌ្ឍន៍ OECD មកប្រទេសអាស៊ាន និងធ្វើសមាហរណកម្មចូលទៅក្នុងខ្សែសង្វាក់តម្លៃតំបន់ និងសកល់ និង **ទី២:** ទទួលស្គាល់អំពីការខិតជិតមកដល់ នៃពេលវេលា និងសកម្មភាព ដែលត្រូវជួយដល់សហគ្រាសធុនតូច និងមធ្យមឱ្យទទួលបានអត្ថប្រយោជន៍ពីឱកាសនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅឆ្នាំ២០១៥ ខាងមុខ ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានវាយតម្លៃខ្ពស់ចំពោះសកម្មភាពការងារដ៏មានតម្លៃរបស់អង្គការ OECD ក្នុងដំណើរការជម្រុញអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ ជាពិសេសការជម្រុញអភិវឌ្ឍន៍វិស័យ SME ។ នៅកម្ពុជាវិស័យសហគ្រាសធុនតូច និងមធ្យម បានដើរតួសំខាន់ណាស់ ក្នុងវិស័យសេដ្ឋកិច្ចជាតិ និងជួយបង្កើតទីផ្សារការងារ ជាច្រើន ។ បច្ចុប្បន្នក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានបង្កើតអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ដែលបានធ្វើការងារផ្តោតលើការលើកកំពស់វិស័យ SME និងសិប្បកម្ម ។ បច្ចុប្បន្នមានអង្គការ JICA ជប៉ុនបានកំពុងជួយក្រសួងក្នុងការរៀបចំគោលនយោបាយលើកទឹកចិត្តវិស័យ SME ។ ទោះជាយ៉ាងណាក្រសួង នៅត្រូវការជំនួយមួយចំនួន ទៀត ។ ឆ្លៀតឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានស្នើឱ្យអង្គការ OECD ជួយគាំទ្រក្រសួងក្នុងការរៀបចំស្ថិតិទិន្នន័យ SME ឡើងវិញ–ស្នើសុំ

ផ្តល់ជំនួយបច្ចេកទេសទាក់ទងនិងការចុះបញ្ជី SME តាមប្រព័ន្ធ Online –លទ្ធភាពទទួលបានហិរញ្ញប្បទាន និងលទ្ធភាពជ្រៀតចូលទីផ្សាររបស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសាទរចំពោះការរៀបចំកិច្ចប្រជុំ ទាក់ទងវិស័យ SME នៅទីរួមខេត្តសៀមរាបខាងមុខ ហើយសង្ឃឹមថាៈតាមរយៈសិក្ខាសាលានេះ នឹងទទួលបានធាតុចូលជាច្រើន សម្រាប់ពង្រឹងវិស័យសហគ្រាសធុនតូច និងមធ្យម នៅក្នុងតំបន់ ហើយកម្ពុជាក៏ទទួលបាននូវបទពិសោធន៍ល្អៗ និងការគាំទ្រនានា ពីដៃគូអភិវឌ្ឍន៍ ដើម្បីភាពលូតលាស់ នៃវិស័យ SME នៅកម្ពុជាផងដែរ ។